# English for Study in Australia
# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## LESSON 8 – Making Australian friends
## មេរៀនទី៨ ៖ ការចងមិត្តភាពជាមួយពលរដ្ឋអូស្ត្រាលី

**STUDY NOTES**
**ឯកសារជំនួយមេរៀន**

<u>តួអង្គ</u>

Angel:
អែនជល ៖ និស្សិតបរទេស មកប្រទេសអូស្ត្រាលីលើកទីមួយ។
Magda:
ម៉េកដា ៖ ជាស្ត្រីដែលស្នាក់នៅផ្ទះរួមគ្នាជាមួយអែនជល។
Kel:
ឃែល ៖ ជាបុរសដែលស្នាក់នៅផ្ទះរួមគ្នាជាមួយអែនជល។

### <u>សាច់រឿង</u>

អែនជល ព្យាយាមផ្តើមការសន្ទនាជាមួយឃែល ប៉ុន្តែ ឃែលមិនបានសំដែងភាពរួសរាយ មករកនាងវិញទាល់តែសោះ។ អែនជល និយាយអំពីបញ្ហានេះប្រាប់ ម៉េកដា ហើយម៉េកដា បានផ្តល់ឱកាសដល់អែនជល ក្នុងការហាត់រៀនការសន្ទនាជាភាសាអង់គ្លេសជាមួយនាង។

### <u>ព័ត៌មាន-ពាក្យសម្រាប់ផ្តើមកិច្ចសន្ទនា</u>

នៅពេលលោកអ្នកចាប់ផ្តើមការសន្ទនាជាមួយនរណាម្នាក់ដែលលោកអ្នកមិនស្គាល់ច្បាស់ លោកអ្នកអាចនិយាយអំពីអាកាសធាតុ ឬអ្វីៗដែលមាននៅជុំវិញខ្លួនលោកអ្នកសិន។ លោកអ្នកក៏អាចសាកសួរព័ត៌មាន ឬស្នើសុំការជួយយកអាសារបន្តិចបន្តួចផងដែរ។ ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗសម្រាប់លោកអ្នក៖

**អាកាសធាតុ ៖**

Great day for a barbecue isn’t it?

ថ្ងៃនេះជាថ្ងៃដ៏ល្អណាស់សម្រាប់ការអាំងសាច់ មិនថាអីចឹងអ្ហេះ?

This rain is good for the garden.

ភ្លៀងនេះមានអត្ថប្រយោជន៍ណាស់ចំពោះសួនច្បារ។

**អ្វីៗដែលនៅជុំវិញខ្លួនលោកអ្នក៖**

The traffic’s bad today, isn’t it.

ចរាចរណ៍ថ្ងៃនេះពិតជាចង្អៀតមែនទែន មិនថាអីចឹងអ្ហេះ?


© RadioAustralia/AMES 2008

That’s a lovely shade of blue.

ពណ៌រាងខៀវអីចឹងគួរឲ្យស្រឡាញ់ណាស់។

**ការសាកសួរព័ត៌មាន៖**

Could you tell me the time, please?

តើអ្នកអាចប្រាប់ខ្ញុំបានទេ ថាម៉ោងប៉ុន្មានហើយ?

Is anyone sitting here?

តើមាននរណាអង្គុយនៅទីនេះហើយឬនៅ?

**ការស្នើសុំការជួយយកអាសារបន្តិចបន្តួច៖**

Excuse me, could you hold this door for me, please?

អត់ទោស តើអ្នកអាចជួយទប់ទ្វារឲ្យខ្ញុំបន្តិចបានទេ?

Excuse me, could you help me with this box, please?.

អត់ទោស តើអ្នកអាចជួយលើកប្រអប់នេះឲ្យខ្ញុំបន្តិចបានទេ?

**<u>ភាសា – សំនួនវោហារ និងឃ្លាដែលមានន័យមិនធម្មតា</u>**

| | |
|---|---|
| To be puffed | ការដកដង្ហើមស្ទើរមិនដល់គ្នា ជាពិសេសក្រោយពេលហាត់ប្រាណរួច។ |
| To get rid of someone or something | បណ្តេញនរណាម្នាក់ចេញ ឬគ្រវែងចោលអ្វីមួយ ។ |
| a creep | ពាក្យពេចន៍ក្នុងទម្រង់អវិជ្ជមាន សម្រាប់ពោលសំដៅទៅនរណាម្នាក់ដែលធ្វើឲ្យអ្នកមានអារម្មណ៍មិនស្រឡះចិត្ត ដោយសារអាកប្បកិរិយារបស់គេ។ |
| “Great day for a barbecue” | ខ្ញុំពិតជាចូលចិត្តអាកាសធាតុបែបនេះណាស់ ព្រោះវាអំណោយផលដល់ការរៀបចំសកម្មភាពនៅខាងក្រៅផ្ទះ ដូជាការអាំងសាច់ជាដើម។ |


© RadioAustralia/AMES 2008

## EXERCISES
## លំហាត់

### ១. វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| barbecue | conversation | delicious |
| favourite | friendly | lamb |
| news | perfect | (to) pretend |
| rude | spicy | stranger |

### ២. ការហាត់រៀនភាសា៖ លំហាត់គំរូ- ការធ្វើតេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីអាចចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវធ្វើតេស្តដើម្បីស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅសរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word that best completes each sentence. Cross one box for each number, eg: ☒

1. Do you __________ if I join your game?

   ☐ worry ☐ mind ☐ think ☐ want

2. Excuse me, _________ you help me with this parcel, please?

   ☐ do ☐ could ☐ are ☐ should

3. Excuse me, ____________ you got the time?

   ☐ Do ☐ will ☐ are ☐ have

4. It's a great day for a picnic, __________ it?

   ☐ doesn't ☐ aren't ☐ isn't ☐ is

5. Excuse me,__________ you mind opening the door?.

   ☐ will ☐ could ☐ are ☐ would


© RadioAustralia/AMES 2008

៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា
សូមហាត់និយាយពាក្យដែលត្រូវពត់អណ្តាត រួចបញ្ចេញសំឡេងឲ្យបានឮៗ ៖

**“Thanks for lunch. It was perfect.”**

## ៤. អាសយដ្ឋានអ៊ីនធើរណិតមានប្រយោជន៍

| | |
|---|---|
| របៀបលេងកីឡាគ្រិកកែត | http://www.peter-upton.co.uk/subrule4.htm |
| របៀបលេងបាល់ទាត់តាមវិន័យអូស្ត្រាលី | http://www.upfromaustralia.com/ausrulfoot.html<br>http://www.nflaussie.com/afl101.html |

ចម្លើយលំហាត់ទី 2:  1) mind   2) could   3) have   4) isn’t   5) would

ABC Radio Australia
radioaustralia.net.au
AMES
www.ames.net.au
© RadioAustralia/AMES 2008